**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Aug-2016, 08:18
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ (កោសលុប)

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើលើកទី ១ របស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) ស្នើសុំកោះហៅសាក្សីបន្ថែមមួយរូប និងទទួលយកកិច្ចសម្ភាសន៍សាក្សីមួយសម្រាប់វគ្គសវនាការស្ដីពីមន្ទីរសន្តិសុខភ្នំក្រោល នៃសំណុំរឿង ០០២/០២**

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្ដី នួន ជា**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

លីវ សុវណ្ណា

Doreen CHEN
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI
Alicia BOOTH

**ផ្ញើជូន៖**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

## I. សេចក្ដីផ្ដើម

1. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក សហមេធាវីការពារក្ដីលោក នួន ជា ("មេធាវីការពារក្ដី") ដាក់សំណើនេះ ("សំណើ") សុំស្ដាប់សក្ខីកម្មសាក្សីម្នាក់បន្ថែមទៀត ទាក់ទិននឹងមន្ទីរសន្តិសុខភ្នំក្រោល និងទទួលយកកិច្ចសម្ភាសន៍មួយរបស់សាក្សីរូបនេះ។

## II. សាវតារ

2. នៅថ្ងៃទី ៨ និង ៩ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្ដី និងភាគី បានដាក់បញ្ជីឈ្មោះដែលបានធ្វើបច្ចុប្បន្នភាពស្ដីពី សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវបានស្នើសុំសម្រាប់សំណុំរឿង ០០២/០២[1]។ នៅថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានចេញបញ្ជីមួយដែលមានសាក្សីចំនួនប្រាំរូបដែលត្រូវបានកំណត់ពេលឲ្យមកផ្ដល់សក្ខីកម្មទាក់ទិននឹងមន្ទីរសន្តិសុខភ្នំក្រោល[2]។ សាក្សីដំបូងបានមកផ្ដល់សក្ខីកម្មនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ហើយសាក្សីម្នាក់ទៀតក៏បានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះរួចហើយដែរ។

3. នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីអំពីសេចក្ដីសម្រេចរបស់ខ្លួនក្នុងការស្ដាប់សក្ខីកម្មសាក្សី 2-TCW-1012 (សៅ សារុន) តាមរយៈប្រព័ន្ធសោតទស្សន៍[3]។

4. នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានដាក់សំណើសុំកោះហៅសាក្សីម្នាក់ឈ្មោះ 2-TCW-1017 [redacted] *ជំនួស* ឬបន្ថែមទៅនឹងបង/ប្អូនប្រុសរបស់គាត់គឺ

---

[1] ឯកសារ **E305/4** "បញ្ជីឈ្មោះ និងព័ត៌មានសង្ខេបដែលបានធ្វើបច្ចុប្បន្នភាព ស្ដីពីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើសុំ" ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤។ ឯកសារ **E305/5** "សាក្សី និងអ្នកជំនាញស្នើឡើងដោយមេធាវីការពារក្ដីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២" ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤។ ឯកសារ **E305/6** "បញ្ជីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសេចក្ដីសង្ខេបសម្រាប់ជំនុំជម្រះក្នុងសំណុំរឿងលេខ ០០២/០២ (ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ចំនួន៥៖ I, II, IIA, III និង IIIA)" ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤។ ឯកសារ **E305/7** "បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ របស់សហមេធាវីការពារក្ដីសម្រាប់សំណុំរឿង ០០២/០២ ជាមួយឧបសម្ព័ន្ធសម្ងាត់" ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤។

[2] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគី ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦។

[3] **E29/476/2** "សេចក្ដីសម្រេច លើការស្ដាប់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់សាក្សីដែលមានរហស្សនាម 2-TCW-1-12" ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦។

សាក្សី 2-TCW-1011 (ខាំ ផាន់ *ហៅ* ផាន វ៉ាន) និងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប , 2-TCCP-1016 (សុន វុត) សម្រាប់វគ្គសវនាការស្តីពីមន្ទីរសន្តិសុខភ្នំក្រោល[4]។ សហព្រះរាជអាជ្ញាបានលើកឡើងថា "ដោយសារតែពាក់កណ្តាលនៃសាក្សីដែលបានស្នើពីមុនមកដោយសហព្រះរាជអាជ្ញាបានទទួលមរណភាព មានមូល ហេតុត្រឹមត្រូវស្របតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង សម្រាប់ការកោះហៅ សុន វុត [2-TCCP-1016] និង [redacted] [2-TCW-1017]"[5]។

5. នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ភាគីត្រូវបានជូនដំណឹងថា ទាក់ទិននឹងសំណើដែលបានដាក់ដោយសហព្រះរាជអាជ្ញា "អង្គជំនុំជម្រះស្នើសុំស្តាប់សារណាតបផ្ទាល់មាត់ *ជំនួស* សារណាតបជាលាយលក្ខណ៍អក្សរ នៅថ្ងៃស្អែក ក្រោយពេលបញ្ចប់សក្ខីកម្មរបស់សាស្ត្រាចារ្យ Hinton"[6]។ នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចផ្ទាល់មាត់ថា អង្គជំនុំជម្រះនឹងស្តាប់សារណាតបផ្ទាល់មាត់ *ជំនួស* សារណាតបជាលាយលក្ខណ៍អក្សរ នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦[7]។

6. នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានស្តាប់សារណាតបផ្ទាល់មាត់ពីភាគី ទាក់ទិននឹងសំណើរបស់ ក.ស.ព សុំកោះហៅសាក្សីទាក់ទិននឹងភ្នំក្រោល។ មេធាវីការពារក្តីមិនបានជំទាស់ទៅនឹងសំណើសុំកោះហៅ [redacted] (2-TCW-1017) ទេ តែបានបញ្ជាក់ថា ទាំង ខាំ ផាន (2-TCW-1011) និងបង/ប្អូនស្រីរបស់គាត់ គួរមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី ដោយសារម្នាក់ក្នុងចំណោមពួកគេមិនគួរផ្តល់សក្ខីកម្ម *ជំនួស* ម្នាក់ទៀតទេ។ លើសពីនេះទៀត មេធាវីការពារក្តីបានជូនដំណឹងមកអង្គជំនុំជម្រះថា សំណើនេះមួយច្បាប់នឹងផ្តល់ជូននៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦[8]។

## III. ច្បាប់ជាធរមាន

[4] ឯកសារ **E390**, "សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យកោះហៅសាក្សីបន្ថែមនៅក្នុងវគ្គនៃអំឡុងពេលសវនាការស្តីពីមន្ទីរសន្តិសុខភ្នំក្រោល" ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ("សំណើរបស់ ក.ស.ព សុំកោះហៅសាក្សីទាក់ទិននឹងភ្នំក្រោល")។

[5] ឯកសារ **E390**, "សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យកោះហៅសាក្សីបន្ថែមនៅក្នុងវគ្គនៃអំឡុងពេលសវនាការស្តីពីមន្ទីរសន្តិសុខភ្នំក្រោល" ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ("សំណើរបស់ ក.ស.ព សុំកោះហៅសាក្សីទាក់ទិននឹងភ្នំក្រោល") នៅត្រង់កថាខណ្ឌលេខ ៨។

[6] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគី ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦។

[7] ប្រតិចារឹកពង្រាងសវនាការថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ៣៦ ដល់ ៣៧ បន្ទាត់ ២០-១។

[8] ប្រតិចារឹកពង្រាងសវនាការថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ៨-៩ បន្ទាត់ ២១-៨។

7. វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងអនុញ្ញាតឱ្យអង្គជំនុំជម្រះ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ភាគី កោះហៅសាក្សីណាម្នាក់ដែល "[ខ្លួនចាត់ទុកថា] មានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត"។ វិធាននេះតម្រូវឱ្យ អង្គជំនុំជម្រះធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣) នៃផ្ទៃក្នុង។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្មនោះពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ។ អង្គជំនុំជម្រះបានបញ្ជាក់ថា ការបើកសវនាការនៅក្នុងសំណុំរឿង ០០២ គឺជាសវនាការបឋម ដែលបានចាប់ផ្តើមនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១។ អង្គជំនុំជម្រះបានសម្រេចថា ទោះបីភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់បុគ្គលម្នាក់ត្រូវបានបង្ហាញ ដោយមាន "ព័ត៌មានតិចតួច" នៅមុនពេលចាប់ផ្តើមការជំនុំជម្រះ ដោយព័ត៌មានលម្អិតមានតែក្រោយពេលចាប់ផ្តើមការជំនុំជម្រះនោះ សក្ខីកម្មដែលបានលើកឡើងនេះនឹងត្រូវចាត់ទុកថា មិនអាចរកបាននៅមុនពេលចាប់ផ្តើមសវនាការ[9]។ ក្នុងករណីដែលសក្ខីកម្មអាចទទួលបាននៅមុនពេលការចាប់ផ្តើមការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សក្ខីកម្មនេះនៅតែអាចទទួលយក "ដរាបណាមានតម្រូវពីផលប្រយោជន៍នៃយុត្តិធម៌ជាពិសេស ដរាបណាភស្តុតាងទាំងនេះជាភស្តុតាងដោះបន្ទុកដែលតម្រូវឱ្យធ្វើការវាយតម្លៃដើម្បីជៀសវាងការសម្រេចសេចក្តីដោយអយុត្តិធម៌"[10] ឬក្នុងករណីដែល សក្ខីកម្មនេះ "ទាក់ទងជិតស្និទ្ធទៅនឹងឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និង ... ផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យវាយតម្លៃប្រភពទាំងនេះរួមគ្នា"[11]។ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ភស្តុតាងដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះគ្រាន់តែត្រូវមានភាពពាក់ព័ន្ធ និងភាពជឿជាក់បាន*តាមការវិភាគបឋម* ប៉ុណ្ណោះ[12]។

8. ដូចគ្នានេះដែរ អនុលោមតាមវិធាន ៨៧(៤) នៅក្នុងករណីមានសំណើសុំឱ្យទទួលយកភស្តុតាងថ្មី

---

[9] ប្រតិចារឹកថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៦ (សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ឯកសារ **E1/363.1**) ទំព័រ ៤១ បន្ទាត់ ៦ - ១២។

[10] ឯកសារ **E307/1** "សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារE307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3) ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៤ កថាខណ្ឌ ៣ *ស្របទឹង* ឯកសារ **E190** "សេចក្តីសម្រេចលើឯកសារថ្មី និងបញ្ហាផ្សេងៗ" ថ្ងៃទី៣០ ខែ មេសា ឆ្នាំ២០១៣ កថាខណ្ឌ ៣៦។

[11] ឯកសារ **E289/2**, "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E289) និងចម្លើយរបស់ ខៀវ សំផន (ឯកសារ E289/1)" ចុះថ្ងៃទី១៤ មិថុនា ឆ្នាំ២០១៣ កថាខណ្ឌ ៣។

[12] ឯកសារ **E313** "សាលក្រម សំណុំរឿង ០០២/០១" ចុះថ្ងៃទី៧ សីហា ឆ្នាំ២០១៤ ("សាលក្រម") កថាខណ្ឌ ២៦។

នៅដំណាក់កាលនានាក្នុងអំឡុងពេលជំនុំជម្រះ ភាគីអាចស្នើសុំអង្គជំនុំជម្រះឲ្យ "ទទួលយកនូវភ័ស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត" ផ្អែកតាមលក្ខខណ្ឌទូទៅនៃវិធាន ៨៧(៣) និង បានថែង "ថា ភ័ស្តុតាងដែលបានស្នើសុំនោះ [...] ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ" ឬ ថា វា "មិនអាចរកបានពីមុនមក ទោះបីជាបានខិតខំប្រឹងប្រែងយ៉ាងសមហេតុផលក្តី"[13]។ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌនៃវិធាន ៨៧(៣) ភ័ស្តុតាងដែលស្នើសុំគ្រាន់តែត្រូវមានភាពពាក់ព័ន្ធ និងជឿជាក់បាន *តាមការវិភាគបឋម* ប៉ុណ្ណោះ[14]។

## IV. **ឧទ្ធិករណ៍**

9. មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះកោះហៅសាក្សី ជិន សារឿន (សាក្សី ក) ឲ្យមកផ្តល់សក្ខីកម្ម ដោយសារគាត់អាចផ្តល់ភ័ស្តុតាងសុក្រឹត្យ និងលម្អិត ពាក់ព័ន្ធនឹងកងពលធំលេខ ៩២០ នៅខេត្តមណ្ឌលគិរី ដោយសារគាត់ធ្លាប់ជាសមាជិកកងវរៈសេនាធំលេខ ៩៣[15] ហើយក្រោយមកបានទៅបម្រើការក្នុងកងវរៈសេនាតូច ៥០២ នៃតំបន់ ១០៥[16]។ ជាសមាជិកកងពលធំលេខ ៩២០ និងកងវរៈសេនាតូច ៥០២ ជិន សារឿន (សាក្សី ក) អាចផ្តល់ព័ត៌មានដែលមានតម្លៃទាក់ទិននឹងរចនាសម្ព័ន្ធ និងឋានានុក្រមបញ្ជាការនៃកងពលធំលេខ ៩២០ ការចាប់ខ្លួនទាហានដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខភ្នំក្រោល រចនាសម្ព័ន្ធ និងឋានានុក្រមបញ្ជាការនៃកងវរៈសេនាតូច ៥០២ មន្ទីរ ស-២១ និងជម្លោះប្រដាប់អាវុធជាមួយវៀតណាម។

---

[13] ឯកសារ **E313** សាលក្រម កថាខណ្ឌ ២៥។

[14] ឯកសារ **E313** សាលក្រម កថាខណ្ឌ ២៦។

[15] ឯកសារ **E3/7960** សេចក្តីសង្ខេបនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជនជាតិភាគិនៅភូមិភាគព្រៃសានក្រោមរបបកម្ពុជាប្រជាធិបតេយ្យ នៅត្រង់លេខ ERN 00851663-664។

[16] ឯកសារ **E3/7960** សេចក្តីសង្ខេបនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជនជាតិភាគិនៅភូមិភាគព្រៃសានក្រោមរបបកម្ពុជាប្រជាធិបតេយ្យ នៅត្រង់លេខ ERN 00851665-666។ នៅក្នុងកថាខណ្ឌដែលពាក់ព័ន្ធ គេបានសរសេរថា ជិន សារឿន (សាក្សី ក) "បម្រើការនៅយោធាតំបន់កងវរៈសេនាតូច ៥២ មកទល់នឹងថ្ងៃវៀតណាមរំដោះ"។ ប្រតិចារឹកផ្ទៃក្នុង និងការបកប្រែ នៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ជិន សារឿន (សាក្សី ក) ដែលបង្ហាញថា "កងវរៈសេនាតូច ៥២" ជាកំហុសផ្នែកបោះពុម្ពដែលគួរតែជា "កងវរៈសេនាតូច ៥០២" ទើបត្រឹមត្រូវ។ នៅក្នុងប្រតិចារឹកផ្ទៃក្នុងនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ជិន សារឿន (សាក្សី ក) នៅត្រង់លេខ 00042513-00042533 ជាភាសាខ្មែរ ជិន សារឿន (សាក្សី ក) និយាយថា៖ "កាលហ្នឹង វរៈសេនាតូចខ្ញុំ ៥០២ មិនមែន ៥២ ទេ។ ផ្កាកឡានយោធា ៥០៣ ឲ្យតែឮសូរឃើញឡានហ្នឹង គឺខ្លាចតែម្តង។ អ្នកល្អក៏ខ្លាច អ្នកអាក្រក់ក៏ខ្លាច ព្រោះថា បើដឹងត្រូវតែចាប់ហ្នឹងកាលហ្នឹង។ ព្រោះខ្លាចអី មួយខ្សែស្វាយ មួយខ្សែខាំភ្លូន មួយខ្សែតាហាម ខ្លាចខ្សែបះបោរគ្នាត្រូវបង្ក្រាប"។

10. មេធាវីការពារក្ដីកត់សម្គាល់ថា ការពាក់ព័ន្ធនៃភ័ស្ដុតាងរបស់ ជិន សារឿន (សាក្សី ក) ទៅនឹងវគ្គសវនាការស្ដីពីមន្ទីរសន្តិសុខភ្នំក្រោល មានកាន់តែច្រើន នៅពេលសហព្រះរាជអាជ្ញាស្នើសុំកោះហៅ សុន វុត (2-TCCP-1016) សម្រាប់វគ្គសនាការនេះ។ មានការលើកឡើងថា សុន វុត (2-TCCP-1016) ធ្លាប់មាន "តួនាទីជាប្រធានកងអនុសេនាធំពិសេសលេខ ៩២០ នៅខេត្តមណ្ឌលគិរី"[17]។ បន្ទាប់មក គាត់ត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខមួយនៅស្រុកកោះញែក[18]។ សហព្រះរាជអាជ្ញាអះអាងថា សុន វុត (2-TCCP-1016) គឺជាអ្នកទោសតែម្នាក់គត់ដែលនៅរស់ពីគុកធំនៅជិតទំនប់ភ្នំក្រោល[19]។ ដោយសន្មតថា ករណីនេះអាចជាការពិតនោះ មេធាវីការពារក្ដីលើកឡើងថា ជាការសំខាន់ដែលត្រូវទទួលបានរូបភាពទូលំទូលាយទូទៅអំពីការចាប់ខ្លួននៅក្នុងកងពលធំលេខ ៩២០ តំបន់ ១០៥ និងអំពីគុកធំនៅជិតទំនប់ភ្នំក្រោល។ ជាអតីតទាហាននៃកងវរៈសេនាធំលេខ ៩៣ កងពលធំលេខ ៩២០ ដែលនៅរស់ និងជាមនុស្សម្នាក់ដែលធ្លាប់ចាប់ខ្លួនទាហានក្នុងកងពលធំលេខ ៩២០ ក្នុងនាមកងវរៈសេនាតូច ៥០២ នោះ ជិន សារឿន (សាក្សី ក) អាចផ្ដល់ភ័ស្ដុតាងបញ្ជាក់បញ្ជាក់ដែល "មានប្រយោជន៍ក្នុងការស្វែងរកការពិត" បាន។ ក្នុងន័យនេះ ដោយសារសំណើនេះត្រូវបានផ្ដួចផ្ដើមមួយផ្នែកពីសំណើរបស់សហព្រះរាជអាជ្ញាសុំកោះហៅ សុន វុត (2-TCCP-1016) នោះ សំណើសុំកោះហៅសាក្សី ជិន សារឿន (សាក្សី ក) មិនមែនថាមិនត្រូវដាក់ទាន់ពេលវេលាទេ។

11. សក្ខីកម្មរបស់សាក្សី ជិន សារឿន (សាក្សី ក) អាចមានសារៈសំខាន់ថែមទៀត ដោយសារលក្ខណៈពិសេសនៃតំបន់ស្វយ័ត ១០៥ ចំពោះវគ្គសនាការស្ដីពីមន្ទីរសន្តិសុខ។ ក្នុងចំណោមភូមិភាគនានា ភូមិភាគឦសានត្រូវបានចោទប្រកាន់ថាបានបញ្ជូនមនុស្សច្រើនជាងគេទៅមន្ទីរ ស-២១ ដោយមនុស្សភាគច្រើនមកពីកងពលធំលេខ ៩២០[20]។ ក្នុងចំណោមមនុស្សចំនួន ៥៣៧ នាក់ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ យ៉ាងហោចណាស់ មនុស្សចំនួន ៤១០ នាក់គឺជាទាហានពី

---

[17] ឯកសារ **E3/6760a** ទំរង់បែបបទសុំព័ត៌មានបន្ថែម ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១០ នៅត្រង់លេខ ERN 00586074។

[18] ឯកសារ **E3/6760a** ទំរង់បែបបទសុំព័ត៌មានបន្ថែម ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១០ នៅត្រង់លេខ ERN 00586074។

[19] ឯកសារ **E390** សំណើរបស់សហព្រះរាជអាជ្ញាសុំកោះហៅសាក្សីសាក្សីបន្ថែមស្ដីពីភ្នំក្រោល នៅត្រង់លេខ ERN 01214277។

[20] ឯកសារ **E3/1664** ការបោសសម្អាតរបស់ពួកខ្មែរក្រហម នៅតំបន់ខ្ពង់រាបខេត្តមណ្ឌលគិរី នៅត្រង់លេខ ERN 00397579 (ភាសាអង់គ្លេស)។

កងពលធំលេខ ៩២០[21]។ ដោយសារតែសាក្សី ជិន សារឿន (សាក្សី ក) ធ្លាប់ធ្វើជាទាហាននៅក្នុងកងវរៈសេនាតូច ៥០២ នៃកងទ័ពតំបន់ ដែលមានសិទ្ធិអំណាចក្នុងការចាប់ខ្លួនទាហានពីកងពលធំលេខ ៩២០ នោះ[22] ជិន សារឿន (សាក្សី ក) អាចផ្តល់ព័ត៌មានយ៉ាងមានតម្លៃអំពីការអនុវត្តគោលនយោបាយនៅពីក្រោយការចាប់ខ្លួនមនុស្ស ជាង ៤០០ នាក់ពីកងពលធំលេខ ៩២០ ពីឆ្នាំ ១៩៧៧ ដល់ ឆ្នាំ ១៩៧៨[23]។

12. ជាពិសេស ជិន សារឿន (សាក្សី ក) ប្រហែលជាអាចផ្តល់ការបញ្ជាក់អំពីចំណងទាក់ទងរវាងការចាប់ខ្លួនឈ្មោះ ស្វាយ និងមនុស្សប្រហែល ៨០ នាក់ទៀត ដែលជាក់ពាក់ព័ន្ធនឹង "ចលនារបស់ ខាំ ភួន" ហើយថា ការចូលរួមពាក់ព័ន្ធរបស់ចលនានោះជាមួយនឹងវៀតណាម[24]។ ពីឆ្នាំ ១៩៧៧ ជិន សារឿន (សាក្សី ក) បានបម្រើការនៅក្នុងកងវរៈសេនាតូច ៥០២ រហូតដល់វៀតណាមចូលមករំដោះ[25]។ ជាសមាជិកនៃកងវរៈសេនាតូច ៥០២ ជិន សារឿន (សាក្សី ក) បានចូលរួមដោយផ្ទាល់ក្នុងការចាប់ខ្លួន ស្វាយ ដោយ "តាមចាប់ស្វាយ នៅភ្នំដោះក្រមុំ"[26]។ ដូចដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានសង្ខេបខាងក្រោម ជិន សារឿន (សាក្សី ក) មានភារកិច្ចទៅចាប់ស្វាយដោយសារតែ:

> ខាំ ភួន នាំវៀតណាមចូលតាមរយៈ ស្វាយ ដែលត្រូវជាក្មួយ ខាំ ភួន។ នៅលាក់ក្បែរភូមិហ្នឹង។ គេចលនាតស៊ូគេនោះណា។ ដល់ចឹងទៅ ហាមគេដឹង។ គេដកសេចក្តីទុកចិត្តគេយកទៅប្រជុំ ... នៅភ្នំពេញ ហើយគេធ្លាប់ ធ្វើការគេដឹងហើយកាលណាគេមិនស្រួល

[21] ឯកសារ **E3/1664** ការបោសសម្អាតរបស់ពួកខ្មែរក្រហម នៅតំបន់ខ្ពង់រាបខេត្តមណ្ឌលគិរី នៅត្រង់លេខ ERN 00397640 (ភាសាអង់គ្លេស)។

[22] ឯកសារ **E3/7960** សេចក្តីសង្ខេបនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជនជាតិភាគតិចនៅភូមិភាគឦសានក្រោមរបបកម្ពុជាប្រជាធិបតេយ្យ នៅត្រង់លេខ ERN 00851665-666។

[23] ឯកសារ **E3/1664** ការបោសសម្អាតរបស់ពួកខ្មែរក្រហម នៅតំបន់ខ្ពង់រាបខេត្តមណ្ឌលគិរី នៅត្រង់លេខ ERN 00397642 (ភាសាអង់គ្លេស)។

[24] ឯកសារ **E3/7960** សេចក្តីសង្ខេបនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជនជាតិភាគតិចនៅភូមិភាគឦសានក្រោមរបបកម្ពុជាប្រជាធិបតេយ្យ នៅត្រង់លេខ ERN 00851665-666។

[25] ឯកសារ **E3/7960** សេចក្តីសង្ខេបនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជនជាតិភាគតិចនៅភូមិភាគឦសានក្រោមរបបកម្ពុជាប្រជាធិបតេយ្យ នៅត្រង់លេខ ERN 00851665-666។

[26] ប្រតិចារឹកផ្ទៃក្នុងនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ជិន សារឿន (សាក្សី ក) នៅត្រង់លេខ ERN 00042513-00042533 ជាភាសាខ្មែរ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០១។

វាយចោលនោះ[27]។

13. ទាក់ទិននឹងការបះបោរផ្ទៃក្នុងដែលមានទំនាក់ទំនងជាមួយវៀតណាម ជិន សារឿន (សាក្សី ក) លើកឡើងថា "គេបំពាក់អាវុធឲ្យអង្គភាពរបស់គាត់នៅពេលដែលត្រូវបង្ក្រាបចលនាបះបោរតែប៉ុណ្ណោះ"[28]។ ក្រោយមក សាក្សីពីររូប គឺឈ្មោះ ចាន់ តូច និង ណេត សាវ៉ាត ត្រូវបានចាប់ខ្លួនជាផ្នែកមួយនៃក្រុមមនុស្សប្រហែលជា ៨០ នាក់ដែលស្ថិតក្នុងខ្សែបណ្ដាញទាំងនោះ និងត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំក្រោល។ ហេតុនេះ ជិន សារឿន (សាក្សី ក) ប្រហែលជាអាចផ្ដល់ព័ត៌មានយ៉ាងមានតម្លៃអំពីសិទ្ធិអំណាច និងវចនាសម្ព័ន្ធបញ្ជាការទាក់ទិននឹងការចាប់ខ្លួនមនុស្សនៅក្នុងតំបន់ ១០៥ ពីឆ្នាំ ១៩៧៧។

14. ភ័ស្តុតាងរបស់សាក្សី ជិន សារឿន (សាក្សី ក) មានភាពពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខភ្នំក្រោល និងជឿជាក់បាន *តាមការវិភាគបឋម*។ វាមានប្រយោជន៍ក្នុងការស្វែងរកការពិត។

15. ដោយពិចារណាឃើញថា សំណើសុំកោះហៅសាក្សី ជិន សារឿន (សាក្សី ក) នេះត្រូវបានផ្ដួចផ្ដើមដោយសំណើរបស់សហព្រះរាជអាជ្ញាសុំកោះហៅ សុន វុត (2-TCCP-1016) នោះ នាពេលនេះ ជាការសំខាន់ដែលកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទិននឹងសាក្សីរូបនេះត្រូវបានបញ្ចូលក្នុងសំណុំរឿង។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ជិន សារឿន (សាក្សី ក) មានជាសាធារណៈហើយ។ ក៏ប៉ុន្តែ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានតែជាភាសាខ្មែរប៉ុណ្ណោះ ដោយមានយោងនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ERN 00042513-00042533។ សេចក្ដីសង្ខេបកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានជាភាសាអង់គ្លេសនៅក្នុងឯកសារ E3/7960 ដែលមានចំណងជើងថា "ជនជាតិភាគតិចនៅភូមិភាគឦសានក្រោមរបបកម្ពុជាប្រជាធិបតេយ្យ"។ ទោះបីជាសាក្សីបានផ្ដល់កិច្ចសម្ភាសន៍ដល់មជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០១ ហើយភ័ស្តុតាងនេះត្រូវបានទទួល និងអាចរកបានមុខពេលចាប់ផ្ដើមសវនាការក៏ដោយ តែមេធាវីការពារក្ដីលើកឡើងថា ដើម្បីជាប្រយោជន៍យុត្តិធម៌ ត្រូវស្ដាប់សក្ខីកម្មរបស់គាត់ដោយផ្ទាល់ ដែលអាចជាសក្ខីកម្មដោះបន្ទុក។

---

[27] ប្រតិចារឹកផ្ទៃក្នុងនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ជិន សារឿន (សាក្សី ក) នៅត្រង់លេខ ERN 00042513-00042533 ជាភាសាខ្មែរ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០១។

[28] ឯកសារ **E3/7960** សេចក្ដីសង្ខេបនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជនជាតិភាគិនៅភូមិភាគឦសានក្រោមរបបកម្ពុជាប្រជាធិបតេយ្យ នៅត្រង់លេខថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ ERN 00450296។

16. មេធាវីការពារក្ដីកត់សម្គាល់បន្ថែមទៀតថា ភាពពាក់ព័ន្ធនៃភ័ស្តុតាងរបស់សាក្សីរូបនេះទៅនឹងវគ្គសវនាការស្ដីពីភ្នំក្រោល ភាពចាំបាច់ក្នុងការស្ដាប់សាក្សីរូបនេះមានកាន់តែខ្លាំងឡើង នៅពេលសហព្រះរាជអាជ្ញាបានសម្រេចនាពេលថ្មីៗក្នុងការស្នើសុំកោះហៅ សុន វុត (2-TCCP-1016) ដែលជាសាក្សីតែម្នាក់គត់ដែលត្រូវបានរំពឹងថានឹងមកផ្ដល់សក្ខីកម្មទាក់ទិននឹងមន្ទីរសន្តិសុខធំនៅភ្នំក្រោល។

## V. សំណូមពរ

17. អនុលោមទៅតាមសំអាងហេតុនានាខាងលើ មេធាវីការស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

(ក) កោះហៅសាក្សី ជិន សារឿន (សាក្សី ក) មកផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ឲ្យបានឆាប់តាមតែអាចធ្វើទៅបាន និង

(ខ) ទទួលយកកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី ជិន សារឿន (សាក្សី ក) ERN 00042513-00042533 ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០១ ធ្វើជាភ័ស្តុតាង។

**សហមេធាវីការពារក្ដី នួន ជា**

សុន អរុណ Victor KOPPE